# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

## ស្តីពីសញ្ញាស័ក្តិ និង ឯកសណ្ឋាន

## ទេសាភិបាល ទេសាភិបាលរងនៃ ធនាគារជាតិនៃកម្ពុជា

ព្រះរាជក្រឹត្យលេខ នស/រកត/០៣០១/០៥០

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធវង្ស អគ្គមហាបុរសរតណ៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានយល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃធនាគារ ជាតិកម្ពុជា
- តាមសំណើរបស់នាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០០

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ត្រូវបានបង្កើតសញ្ញាស័ក្តិ និងឯកសណ្ឋានសំរាប់សំគាល់ទេសាភិបាលនិងទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ។

**មាត្រា ២ .-**

សញ្ញាស័ក្តិ និង ឯកសណ្ឋាននេះ សំរាប់ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និង ពិធីផ្លូវការផ្សេងៗ ។

## ជំពូកទី ២

## សញ្ញាស័ក្តិ

**មាត្រា ៣ .-**

សញ្ញាស័ក្តិសំរាប់ទេសាភិបាល និង ទេសាភិបាលរង ត្រូវបានកំណត់ដូចតទៅ :

**១-សំរាប់ទេសាភិបាល**

ក-ស័ក្តិស្មា :

ស័ក្តិស្មាមានលក្ខណៈសំគាល់ដូចតទៅ :

$ក_{១}$ : មានក្បាច់ភ្ញីទេស ពណ៌មាស មានរាងជាវល្លិ៍ មានដើម ស្លឹក ផ្លែនិងផ្កា នៅខាងចុងផ្នែកខាងលើនៃក្បាច់ មានផ្កាឈូកមួយទង មានត្របក ៣

$ក_{២}$ : លើផ្កាឈូក មានសញ្ញាធនាគារជាតិនៃកម្ពុជាពណ៌មាសមួយ

$ក_{៣}$ : លើសញ្ញាធនាគារជាតិនៃកម្ពុជា មានឡេវរូបព្រះសង្ហារនៃព្រះរាជាណាចក្រកម្ពុជា ពណ៌មាសមួយ

$ក_{៤}$ : នៅជុំវិញរូបនៃចំណុច $ក_{១}$ -$ក_{២}$ -$ក_{៣}$ មានពួរវេញមួយខ្សែព័ទ្ធជុំវិញ ។ នៅជុំវិញពួរវេញ មានសន្លឹកក្បាច់ភ្ញីទេសដាក់រាយគ្នាជាជួរ ជាលំអ ។ នៅបាតក្រោម មានក្បាច់ផ្កាដួង ១ ជួរ ។ នៅជុំវិញសន្លឹកក្បាច់ភ្ញីទេសនិងផ្កាដួង មានឆ្នូតពួរវេញ ៣ ជាសញ្ញា ឋានន្តរស័ក្តិទេសាភិបាល ។

ខ្នាតស័ក្តិស្មាត្រូវបានកំណត់ដូចខាងក្រោម :

-បាតក្រោមប្រវែង [illegible] សង្ទីម៉ែត្រ

-ទទឹងមុខកាត់ផ្នែកខាងលើប្រវែង ៤។៦០ សង្ទីម៉ែត្រ មានរាងកោងជាមុំទាល

-បណ្តោយពីលើដល់បាតក្រោម ប្រវែង ១៣ សង្ទីម៉ែត្រ

-ផ្ទៃ : ក្រណាត់កម្ទីពណ៌ខ្មៅ ។

ខ-ស័ក្តិចុងកអាវ :

ស័ក្តិចុងកអាវស្មាមានលក្ខណៈសំគាល់ដូចតទៅ :

$ខ_{១}$ : មានសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌មាស ១ នៅខាងដើម

ខ₂ : ក្បាច់ភ្ញីទេស មានរាងជា ដើម ស្លឹក ផ្លែ

ខ₃ : មានផ្កាឈូក ១ទង មានត្របក ៣ នៅខាងដើមក្បាច់ភ្ញីទេស

ខ₄ : នៅជុំវិញរូបភាពនៃចំណុច ខ₁-ខ₂ -ខ₃ មានក្លួតពួរវេញ ១ ឆ្លូតព័ទ្ធជុំវិញ

ខ₅ : នៅចំហៀងខាងមុខ និងខាងលើនៃពួរវេញ មានសន្លឹក ក្បាច់ភ្ញីទេស ដាក់រាយគ្នាជា លំអងរជាយ

ខ₆ : នៅផ្នែកខាងមុខ និង ខាងលើនៃសន្លឹកក្បាច់ភ្ញីទេស មានឆ្លូតពួរវេញ ៣ ជាសញ្ញាឋានន្តរសក្តិ ទេសាភិបាល ។

ខ្នាតស័ក្តិចុងកអាវត្រូវបានកំណត់ដូចខាងក្រោមនេះ :

-មានរាងប្រលេឡូក្រាម

-បណ្តោយប្រវែង ១១ សង្ទីម៉ែត្រ

-ទទឹងប្រវែង ៤.៨ សង្ទីម៉ែត្រ

-ផ្ទៃ : ក្រណាត់កម្ពីពណ៌ខ្មៅ

គ-ស័ក្តិចុងដៃអាវទាំងសងខាង

ស័ក្តិចុងដៃអាវទាំងសងខាងមានលក្ខណៈសំគាល់ដូចតទៅ :

គ₁ : មានក្បាច់ភ្ញីទេស រាងជាវល្លិ៍ មានដើម ស្លឹក ផ្លែ និង ផ្កា នៅខាងដើមក្បាច់ភ្ញីទេស មានផ្កាឈូក ១ ទង បើកជាត្របក ៣

គ₂ : មានក្បាច់ភ្ញីទេស មានពួរវេញ ១ ឆ្លូតព័ទ្ធជុំវិញក្បាច់ភ្ញីទេស

គ₃ : មានសន្លឹកក្បាច់ភ្ញីទេស ២០ សន្លឹក ដាក់រាយជាជួរអមពួរវេញ ជាលំអងរជាយ

គ₄ : នៅចុងខាងក្រោបង្អស់នៃស័ក្តិ ផ្នែកខាងលើ និងសងខាង មានឆ្លូតពណ៌មាស ៣ ជាសញ្ញាឋានន្តរស័ក្តិ ទេសាភិបាល ។

ខ្នាតស័ក្តិចុងដៃអាវទាំងសងខាងត្រូវបានកំណត់ដូចខាងក្រោមនេះ :

-មានបួនជ្រុងទ្រវែង

-បណ្តោយប្រវែង ៣២ សង្ទីម៉ែត្រ

-ទទឹងប្រវែង ១១ សង្ទីម៉ែត្រ

-ផ្ទៃ : ក្រណាត់កម្ទីពណ៌ខ្មៅ

-រូបគំនូរស័ក្តិស្នា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវ សំរាប់ទេសាភិបាល មានដូចក្នុងឧបសម្ព័ន្ធទី១ នៃព្រះរាជក្រឹត្យនេះ ។

**២-សំរាប់ទេសាភិបាលរង**

ក-ស័ក្តិស្នា :

ស័ក្តិស្នាមានលក្ខណៈសំគាល់ដូចតទៅ :

$ក_{១}$ : មានក្បាច់ភ្ញីទេស ពណ៌មាស មានរាងជាវល្លិ៍ មានដើម ស្លឹក ផ្លែនិងផ្កា នៅខាងចុងផ្នែកខាងលើនៃក្បាច់ មានផ្កាឈូកមួយទង មានត្របក ៣

$ក_{២}$ : លើផ្កាឈូក មានសញ្ញាធនាគារជាតិនៃកម្ពុជាពណ៌មាសមួយ

$ក_{៣}$ : លើសញ្ញាធនាគារជាតិនៃកម្ពុជា មានឡេវរូបព្រះសង្ហារនៃព្រះរាជាណាចក្រកម្ពុជាពណ៌មាសមួយ

$ក_{៤}$ : នៅជុំវិញរូបនៃចំណុច $ក_{១}$ $ក_{២}$ $ក_{៣}$ មានពួរវេញមួយខ្សែព័ទ្ធជុំវិញ ។ នៅជុំវិញពួរវេញមានសន្លឹកក្បាច់ភ្ញីទេសដាក់រាយគ្នាជាជួរ ជាលំអ ។ នៅបាតក្រោម មានក្បាច់ផ្កាដូង ១ ជួរ ហើយនៅជុំវិញសន្លឹកក្បាច់ភ្ញីទេសនិងផ្កាដូងមាន ឆ្នូតពួរវេញ ២ ជាសញ្ញាបាននូវស័ក្តិ ទេសាភិបាលរង ។

ខ្នាតស័ក្តិស្នាត្រូវបានកំណត់ដូចខាងក្រោម :

-បាតក្រោមប្រវែង ៦ សង្ទីម៉ែត្រ

-ទទឹងមុខកាត់ផ្នែកខាងលើប្រវែង ៤.៦០ សង្ទីម៉ែត្រ មានរាងកោងជាមុំទាល

-បណ្តោយពីលើដល់បាតក្រោមប្រវែង ១៣ សង្ទីម៉ែត្រ

-ផ្ទៃ : ក្រណាត់កម្ទីពណ៌ខ្មៅ ។

ខ-ស័ក្តិចុងកអាវ :

ស័ក្តិចុងដៃអាវមានលក្ខណៈសំគាល់ដូចតទៅ :

$ខ_{១}$ : មានសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌មាស ១ នៅខាងដើម

$ខ_{២}$ : ក្បាច់ភ្ញីទេស មានរាងជា ដើម ស្លឹក ផ្លែ

$ខ_{៣}$ : មានផ្កាឈូក ១ ទង មានត្របក ៣ នៅខាងដើមក្បាច់ភ្ញីទេស

ខ៤ : នៅជុំវិញរូបភាពនៃចំណុច ខ១ ខ២ ខ៣ មានឆ្នូតពួរវេញ ១ ឆ្នូតព័ទ្ធជុំវិញ

ខ៥ : នៅចំហៀងខាងមុខ និងខាងលើនៃពួរវេញ មានសន្លឹក ក្បាច់ភ្ញីទេស១៣ ដាក់ រាយគ្នាជាលំអជរជាយ

ខ៦ : នៅផ្នែកខាងមុខ និង ខាងលើនៃសន្លឹកក្បាច់ភ្ញីទេស មានឆ្នូតពួរវេញ ២ សញ្ញាឋានន្តរស័ក្តិ ទេសាភិបាលរង ។

ខ្នាតស័ក្តិចុងដៃអាវត្រូវបានកំណត់ដូចខាងក្រោមនេះ :

-មានរាងប្រលេឡូក្រាម

-បណ្តោយប្រវែង ១១ សង្ទីម៉ែត្រ

-ទទឹងប្រវែង ៤.៨ សង្ទីម៉ែត្រ

-ផ្ទៃ : ក្រណាត់កម្ពីពណ៌ខ្មៅ

គ-ស័ក្តិចុងដៃអាវទាំងសងខាង :

ស័ក្តិចុងដៃអាវទាំងសងខាងមានលក្ខណៈសំគាល់ដូចតទៅ :

គ១ : មានក្បាច់ភ្ញីទេស រាងជាវល្លិ៍ មានដើម ស្លឹក ផ្លែ និង ផ្កា ហើយនៅខាងដើមក្បាច់ ភ្ញីទេស មានផ្កាឈូក ១ ទង បើកជាត្របក ៣

គ២ : មានក្បាច់ភ្ញីទេស មានពួរវេញ ១ ឆ្នូតព័ទ្ធជុំវិញក្បាច់ភ្ញីទេស

គ៣ : មានស្លឹកក្បាច់ភ្ញីទេស ២០ សន្លឹក ដាក់រាយជាជួរអមពួរវេញ ជាលំអជរជាយ

គ៤ : នៅចុងខាងក្រៅបង្អស់នៃស័ក្តិ ផ្នែកខាងលើនិងសងខាង មានឆ្នូតពណ៌មាស ២ ជា សញ្ញាឋានន្តរស័ក្តិ ទេសាភិបាលរង ។

ខ្នាតចុងដៃអាវទាំងសងខាងត្រូវបានកំណត់ដូចខាងក្រោម :

-មានបួនជ្រុងទ្រវែង

-បណ្តោយប្រវែង ៣២ សង្ទីម៉ែត្រ

-ទទឹងប្រវែង ១១ សង្ទីម៉ែត្រ

-ផ្ទៃ : ក្រណាត់កម្ពីពណ៌ខ្មៅ

-រូបគំនូរស័ក្តិស្មា ស័ក្តិចុងអាវ ស័ក្តិចុងកដៃអាវ សំរាប់ទេសាភិបាលរង មានដូចក្នុងឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យនេះ ។

ដោយឡែក ស័ក្តិស្មា ស័ក្តិចុងកអាវ និងស័ក្តិចុងដៃអាវទាំងសងខាង របស់នារី មានទំហំតូច ដូចខាងក្រោមនេះ :

-ចំពោះស័ក្តិស្មាអាចមានទំហំ ៨០ % ៨៥ % ៩០ % នៃទំហំស័ក្តិស្មារបស់បុរស អាស្រ័យលើមាឌរបស់នារី

-ស័ក្តិចុងដៃអាវ អាចមានទំហំស្មើនឹង ៧០ % ទៅ ៧៥ % នៃទំហំស័ក្តិចុងដៃអាវរបស់បុរសអាស្រ័យលើមាឌរបស់នារី

-ស័ក្តិកអាវ មានទំហំទទឹង ៣ សង្ទីម៉ែត្រ ទៅ ៣.៥ សង្ទីម៉ែត្រ អាស្រ័យលើមាឌរបស់នារី

## ជំពូកទី ៣

## ប្រភេទឯកសណ្ឋាន និង ការប្រើប្រាស់

**មាត្រា ៤ .-**

ប្រភេទឯកសណ្ឋានសំរាប់ទេសាភិបាល និង ទេសាភិបាលរង ត្រូវបានកំណត់ដូច ខាងក្រោម :

**១.-ឯកសណ្ឋានផ្លូវការ**

ក-ចំពោះបុរស :

-អាវកុដពណ៌ស កត្រង់ កាត់រាងអាវធំ គ្មានផែកខ្នង ចុងកអាវទាំងសងខាងមានស័ក្តិតាមឋានន្តរស័ក្តិ មានបន្ទះលើស្មាសំរាប់ដាក់ស័ក្តិ មានហោប៉ៅចោះ មានគំរបរាងស្លឹកពោធិខាងលើពីរខាងក្រោមពីរ ។ អាវដៃវែង ចុងដៃអាវមានស័ក្តិតាមឋានន្តរស័ក្តិ អាវបិទឡេវមុខដោយដាក់ឡេវរូបព្រះរាជសង្ហារចំនួនប្រាំពីរ ។

-ខោជើងវែងពណ៌ស ស្បែកជើងយ្លប់ពណ៌ខ្មៅ និង ស្រោមជើងពណ៌ខ្មៅ ។

ខ-ចំពោះនារី :

-អាវជីបរាងពណ៌ស ដោយប្រើសាច់ក្រណាត់ដូចឈុតអាវរបស់បុរស កតាំងគ្មានផែកខ្នង បិទឡេវមុខ និងមានរាងមូលនៅជាយអាវខាងក្រោម ។ ចុងកអាវទាំងសងខាងមានស័ក្តិតាមឋានន្តរស័ក្តិ មានបន្ទះលើស្មាសំរាប់ដាក់ស័ក្តិ គ្មានហោប៉ៅ អាវដៃវែងត្រឹមកែ្តកគោលដៃ ចុងដៃអាវមានស័ក្តិតាមឋានន្តរស័ក្តិតាមឋានន្តរស័ក្តិ ដាក់ឡេវរូបព្រះសង្ហារចំនួនប្រាំ ។

ឯកសណ្ឋានផ្លូវការ មាន ៣ ប្រភេទ :

-ប្រភេទលេខ ១ : ប្រើសំពត់សំឡយអំពីជាមួងពណ៌តាមថ្ងៃ មានចាក់ជើងអំពីសូត្រពណ៌ខ្ចីជាងពណ៌សំពត់

-ប្រភេទលេខ ២ : ប្រើសំពត់សំឡុយអំពីជាមួងពណ៌តាមថ្ងៃ ចាក់ជើងសែសយពណ៌ ឬទីនមាស តាមក្បាច់ជើងឯកភាពគ្នា

-ប្រភេទលេខ ៣ : ប្រើសំពត់សំឡុយអំពីហូល តាមគោមឯកភាពគ្នា

-ស្បែកជើងអេស្កាប៉ាំងយ្ហុបមុខនិងជិតកែងពណ៌ស កាបូបយួរដៃពណ៌ស សំរាប់ពេលព្រឹក ដល់ ថ្ងៃត្រង់

-ស្បែកជើងអេស្កាប៉ាំងយ្ហុបមុខនិងជិតកែងពណ៌ខ្មៅ កាបូបយួរដៃពណ៌ខ្មៅ សំរាប់ពេល ល្ងាច ។

គំរូឯកសណ្ឋានសំរាប់ទេសាភិបាល ទេសាភិបាលរង ទាំងបុរសទាំងនារីមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ទី ៣ នៃព្រះរាជក្រឹត្យនេះ ។

**២-ឯកសណ្ឋានសំរាប់ប្រពៃណីជាតិ**

ក-ចំពោះបុរស :

-អាវកុដពណ៌ស កត្រង់ កាត់រាងអាវធំ គ្មានផែកខ្នង ចុងកអាវទាំងសងខាងមានស័ក្តិតាម ឋានន្តរស័ក្តិ មានបន្ទះលើស្មាសំរាប់ដាក់ស័ក្តិ មានហោប៉ៅចោះ មានគំរបរាងស្លឹកពោធិខាងលើពីរ ខាង ក្រោមពីរ ។ អាវដៃវែង ចុងដៃមានស័ក្តិតាមឋានន្តរស័ក្តិ អាវបិទមុខដោយដាក់ឡេវរូបព្រះសង្ហារ ចំនួនប្រាំពីរ ។

-សំពត់ជាមួងចងក្បិនពណ៌តាមថ្ងៃ ស្បែកជើងយ្ហុបពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅដល់ ជង្គង់ ។

ខ-ចំពោះនារី :

-អាវជីបរាងអំពីសូត្រពណ៌សដៃវែងត្រឹមកែ្ងកគោលដៃ កវាលមូលខាងមុខធ្លាក់ចុះពីក្បាល ឆ្អឹងដងកាំបិត ១.៥ សង្ទីម៉ែត្រ និងត្រង់ស្មាឃ្លាតពីគល់កប្រមាណ ២.៥ សង្ទីម៉ែត្រទៅ ៣.00 សង្ទីម៉ែត្រ អាស្រ័យទៅតាមមាឌរបស់នារី គ្មានស័ក្តិស្មាស័ក្តិចុងកអាវ ប៉ុន្តែមានស័ក្តិចុងដៃអាវទាំង សងខាងតាមឋានន្តរស័ក្តិ

-ពានាក្រមាអំពីសូត្រ ដែលមានផ្ទៃពណ៌ខ្ចីជាងសំពត់ ចាក់ជាយតាមបណ្តោយក្រមានិងចុង ជាយទទឹងក្រមាអំពីសូត្រ ពណ៌ចាស់ដូចសំពត់ តាមក្បាច់ឯកភាពគ្នា ឬក្រមាសូត្រពណ៌ស៊ីន្ទូន តាមការ កំណត់របស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ ដោយប្រើកន្ទាស់សំរាប់ខ្ទាស់ក្រមា ពានា ជាកន្ទាស់អំពីសញ្ញារាជរដ្ឋាភិបាល ដែលមានទំហំទទឹង ៥ សង្ទីម៉ែត្រ និងកំពស់ ៧ សង្ទីម៉ែត្រ ។

ឯកសណ្ឋានប្រពៃណី មាន ២ ប្រភេទ :

-ប្រភេទលេខ ១ : ប្រើសំពត់ជាមួងចងក្បិន ពណ៌តាមថ្ងៃ និងពានាក្រមា

-ប្រភេទលេខ ២ : ប្រើសំពត់ហូលតាមគោមឯកភាពគ្នា និងពានាក្រមាពណ៌ស៊ីទ្ធន

-ស្បែកជើងពណ៌ស និងកាបូបយួរដៃពណ៌ស សំរាប់ពេលព្រឹក ដល់ថ្ងៃត្រង់

-ស្បែកជើងពណ៌ខ្មៅ និងកាបូបយួរដៃពណ៌ខ្មៅ សំរាប់ពេលល្ងាច ។

រូបគំនូរឯកសណ្ឋានប្រពៃណីសំរាប់ទេសាភិបាល និងទេសាភិបាលរង ទាំងបុរស ទាំងនារី មានដូចក្នុង ឧបសម្ព័ន្ធទី ៤ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥ .-**

ការប្រើប្រាស់ឯកសណ្ឋានសំរាប់ទេសាភិបាល និង ទេសាភិបាលរង ត្រូវបានកំណត់ដូចខាងក្រោម :

-ឯកសណ្ឋានផ្លូវការសំរាប់ប្រើប្រាស់ក្នុងឱកាស ទិវាបុណ្យជាតិ និង ពិធីផ្លូវការផ្សេងៗទៀតរបស់រដ្ឋ

-ឯកសណ្ឋានប្រពៃណីជាតិសំរាប់ប្រើប្រាស់ ក្នុងឱកាសទិវាបុណ្យប្រពៃណីជាតិ និង សាសនា ដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម និងទីកន្លែងផ្សេងៗ

ឯកសណ្ឋានទាំងពីរប្រភេទខាងលើនេះ ត្រូវស្លៀកពាក់ទៅតាមការកំណត់របស់គណៈកម្មាធិការបុណ្យជាតិ និង អន្តរជាតិ ។

**មាត្រា ៦ .-**

ការចំណាយសំរាប់ផលិតស័ក្តិ ជាបន្ទុករបស់ធនាគារជាតិនៃកម្ពុជា ។ រីឯ ការចំណាយសំរាប់ឯកសណ្ឋាន ជាសម្លៀកបំពាក់ ស្បែកជើង និងកាបូប ជាបន្ទុករបស់សាមីខ្លួនផ្ទាល់ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៧ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៨ .-

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០១

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

**ឯកសណ្ឋានផ្លូវការ**

ឧបសម្ព័ន្ធទី១ នៃព្រះរាជក្រឹត្យលេខ...៥៤...៨.១៧...
ចុះថ្ងៃទី២០ ខែ មីនា ឆ្នាំ២០០១...ស្តីពីសញ្ញាស័ក្តិ
និងឯកសណ្ឋានរបស់ទេសាភិបាលធនាគារជាតិ នៃកម្ពុជា

## ទេសាភិបាល

ស័ក្តិ ស្មា



ស័ក្តិ កអាវ



ស័ក្តិដៃអាវ



**ឯកសណ្ឋានផ្លូវការ**

ឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យលេខ........នស/រកត/០៣/០១/៨៤..

ចុះថ្ងៃទី...២០....ខែ...មីនា.....ឆ្នាំ...២០០១...ស្តីពីសញ្ញាសក្តិ

និងឯកសណ្ឋានរបស់ទេសាភិបាលរងធនាគារជាតិ នៃ កម្ពុជា

# ទេសាភិបាលរង

សក្តិ ស្មា



សក្តិ កអាវ



សក្តិដៃអាវ





**ឯកសណ្ឋានផ្លូវការ**

ឧបសម្ព័ន្ធទី៣ នៃព្រះរាជក្រឹត្យលេខ....នស/...ត.៧..
ចុះថ្ងៃទី..១៤..ខែ..មីនា...ឆ្នាំ..២០០១..ស្តីពីសញ្ញាស័ក្តិ
និងឯកសណ្ឋានរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា



**ឯកសណ្ឋានប្រពៃណី**

ឧបសម្ព័ន្ធទី៤ នៃព្រះរាជក្រឹត្យលេខ...៥៤...ន.ក្រ....
ចុះថ្ងៃទី១០..ខែ.មីនា....ឆ្នាំ.២០០១..ស្តីពីសញ្ញាស័ក្តិ
និងឯកសណ្ឋានរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា